01072983

002/19-09-2007-ECCC/TC
E1/266

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 27 / 03 / 2015
ម៉ោង (Time/Heure): 14:25
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសដ

ថ្ងៃ ព្រហស្បតិ៍ទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥

**សវនាការលើភស្តុតាង - ថ្ងៃ ២៤៧**

រៀបចំដោយ៖ **ជា ស៊ីចាន់** និង **Roger PHILLIPS**

| **កំណត់ហេតុអ្នកចូលរួម** |
|---|
| ចំពោះមុខ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យ៉ា សុខន, ចៅក្រម Claudia FENZ, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Martin KAROPKIN |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, កញ្ញា ជា ស៊ីវហ៊ាង, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក Nicholas KOUMJIAN, លោក សេង លាង, លោក Dale LYSAK, លោក Vincent de Wilde d'ESTMAEL |
| ជនជាប់ចោទ៖ លោក នួន ជា (ពីបន្ទប់ឃុំខ្លួន), លោក ខៀវ សំផន |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឱ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |
| ក្រុមមេធាវីប្រចាំការសម្រាប់ជនជាប់ចោទ ខៀវ សំផន៖ លោកស្រី ទូច វរល័ក្ស, លោក Calvin SAUNDERS |
| មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី Marie GUIRAUD, លោក វ៉ែនពៅ, លោក ឡោ ជុនធី, លោកស្រី ស៊ីន សុវ៉ិន, លោក ហុង គីមសួន |

| |
|---|
| សាក្សី/ដើមបណ្តឹង ៖ ស្រី ថន ហៅ ឌុច (2-TCW-944) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អរុណ, លោកស្រី សួ សុទ្ធារី |
| ផ្សេងៗ៖ លោក Russell HOPKINS, កញ្ញា ស្រី ណាក់, លោក វ៉ាត សុម៉ៅ, កញ្ញា Sara ERJAVEC, លោក Yassir Al-Khudayri, លោក ឌុច ផារី (មេធាវីប្រឹក្សា) |

| **ពេលវេលាទូទៅរបស់តុលាការ៖** | | |
|---|---|---|
| ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥ | ចាប់ផ្តើមម៉ោង៖ ០៩.០៩ | បញ្ចប់ម៉ោង៖១១.៤៥ |
| សម្រាកពេលព្រឹក | ចាប់ផ្តើមម៉ោង៖ ១០.00 | បញ្ចប់ម៉ោង៖ ១០.៣០ |
| សម្រាកថ្ងៃត្រង់ | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| សម្រាកពេលរសៀល | ចាប់ផ្តើមម៉ោង៖ គ្មាន | បញ្ចប់ម៉ោង៖ គ្មាន |
| | ចំនួនម៉ោងសរុបរបស់តុលាការ៖ | ០២ម៉ោង និង ០៦ នាទី |

| **កិច្ចដំណើរការនីតិវិធីផ្សេងទៀត** | | | |
|---|---|---|---|
| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្តើម | ម៉ោងបញ្ចប់ |
| ការប្រកាសបើកកិច្ចដំណើរការសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី | អង្គជំនុំជម្រះ<br>ក្រឡាបញ្ជី | ០៩.០៩ | ០៩.១១ |
| សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ | មេធាវីការពារក្តី នួន ជា | ០៩.១១ | ០៩.១៣ |
| សេចក្តីសម្រេចផ្ទាល់មាត់អំពីការធ្វើសវនាការជាអសាធារណៈ | អង្គជំនុំជម្រះ | ០៩.១៣ | ០៩.១៥ |
| កិច្ចពិភាក្សាពាក់ព័ន្ធនឹងសំណើសុំវិធានការការពារសម្រាប់សាក្សី 2-TCW-944 (សវនាការអសាធារណៈ) | អង្គជំនុំជម្រះ<br><br>សហព្រះរាជអាជ្ញា<br><br>សហមេធាវីនាំមុខ<br>មេធាវីការពារក្តី នួន ជា<br><br>មេធាវីការពារក្តី ខៀវ សំផន | ០៩.១៧<br>០៩.៥២<br>០៩.២០<br>០៩.៣៩<br>០៩.២៥<br>០៩.២៧<br>០៩.៥១<br>០៩.៣២ | ០៩.១៩<br>០៩.៥៩<br>០៩.២៥<br>០៩.៤៧<br>០៩.២៧<br>០៩.៣២<br>០៩.៥២<br>០៩.៣៩ |

| | | | |
|---|---|---|---|
| | មេធាវីប្រឹក្សារបស់សាក្សី | ០៩.៤៨ | ០៩.៥១ |
| សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំវិធានការការពារ | អង្គជំនុំជម្រះ | ១០.៣១ | ១០.៣២ |
| ការតាំងសំណួរទៅកាន់សាក្សី ស្រី ថន ហៅ ឌុច (2-TCW-944) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា | ១០.៣២<br>១០.៤១ | ១០.៤១<br>១១.៤០ |
| ការណែនាំបន្ថែមទាក់ទងនឹងវិធានការការពារដែលផ្តល់ឱ្យសាក្សី | អង្គជំនុំជម្រះ | ១១.៤០ | ១១.៤១ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ និងការប្រកាសពីវត្តមានរបស់ភាគី</u>**

ប្រធានអង្គជំនុំជម្រះប្រកាសបើកកិច្ចដំណើរការនីតិវិធីសវនាការ។ ក្រឡាបញ្ជីរាយការណ៍ថាគ្រប់ភាគីទាំងអស់មានវត្តមាន។ ជនជាប់ចោទ នួន ជា មានវត្តមាននៅក្នុងបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ។

**<u>សំណើរបស់ នួន ជា ស្នើសុំតាមដានកិច្ចដំណើការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ</u>**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមសំណើរបស់ជនជាប់ចោទ នួន ជា ក្នុងការលះបង់សិទ្ធចូលរួមកិច្ចដំណើការនីតិវិធីសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ និងអនុញ្ញាតឱ្យគាត់តាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់អំពីការធ្វើសវនាការជាអសាធារណៈ</u>**

អង្គជំនុំជម្រះសម្រេចថាកិច្ចពិភាក្សាពាក់ព័ន្ធនឹងសំណើសុំវិធានការការពាររបស់សាក្សី នឹងធ្វើឡើងជាអសាធារណៈ។

**<u>កិច្ចពិភាក្សាពាក់ព័ន្ធនឹងសំណើសុំវិធានការការពារសម្រាប់សាក្សី 2-TCW-944</u>**

សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីគាំទ្រទៅលើសំណើសុំវិធានការការពារសម្រាប់សាក្សី។ មេធាវីការពារក្តី នួន ជា បានចង្អុលបង្ហាញថាខ្លួនមិនជំទាស់ទៅនឹងវិធានការការពារដែលបានស្នើសុំនោះទេ ហើយបានសួរបញ្ជាក់ថាតើជនជាប់ចោទ នួន ជា អាចមើលឃើញរូបភាពពេញលេញរបស់សាក្សីដែលមិនបានបំប្លែង ដែរឬទេ។ មេធាវីការពារក្តី ខៀវ សំផន កត់សម្គាល់ពីសារៈសំខាន់នៃសវនាការជាសាធារណៈដោយបញ្ជាក់ថាខ្លួនមិនបដិសេធទៅនឹងសំណើ

នេះទេ។ មេធាវីប្រឹក្សារបស់សាក្សីបានបកស្រាយអំពីការព្រួយបារម្ភរបស់សាក្សីហើយបានស្នើសុំមិនបញ្ចេញអាសយដ្ឋានរបស់សាក្សី ហើយស្នើឱ្យបំភ្លែងមុខរបស់សាក្សីនៅលើអេក្រង់ផ្សព្វផ្សាយដើម្បីជៀសវាងមិនឱ្យសាធារណជនមើលឃើញ។

**<u>សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំវិធានការការពារ</u>**

អង្គជំនុំជម្រះយល់ព្រមលើសំណើសុំវិធានការពារដែលស្នើមិនឱ្យបញ្ចេញព័ត៌មានស្តីពីអាសយដ្ឋាន និងរូបភាពរបស់សាក្សីទៅសាធារណជន។ អង្គជំនុំជម្រះបង្គាប់ឱ្យផ្នែកសោធទស្សន៍បម្លែងរូបភាពមុខរបស់សាក្សី នៅក្នុងអំឡុងពេលដំណើរការសវនាការ។

**<u>ការតាំងសំណួរទៅកាន់សាក្សី ស្រី ថន</u> (2-TCW-944)**

ប្រធានអង្គជំនុំជម្រះ បានតាំងសំណួរបឋមមួយចំនួនទៅកាន់សាក្សី ស្រី ថន (2-TCW-944)។ បន្ទាប់មកសហព្រះរាជអាជ្ញា បានធ្វើការតាំងសំនួរ។

**<u>កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង</u>**

| លេខ E3 | លេខ កសចស | ERN (KH, ENG, FR) | ចំណងជើងឯកសារ | ចំណាត់ថ្នាក់ | ERN ខ្មែរ | ERN អង់គ្លេស | ERN បារាំង |
|---|---|---|---|---|---|---|---|
| E3/5852 | D125/129 | 00224787-00224792; 00231672-00231677; 00234573-00234578 | Written Record of Interview of SREI Than | P | 00224788; 00224789; 00224790; 00224791 | 00231673; 00231674; 00231675; | 002345740 0234575; 00234576 |
| E319.1.25 | | 00960642-00960650; 00970066-00970076; 00973030-00973038 | Written Record of Witness Interview Srei Than | S | 00960644 00960645 | 00970068 00970070 | 00973032 00973033 |
| E3/5153 | | 00172042-00172045 00205087-00205091 00205092-00205096 | Written Record of Interview of KEO Chandara | P | 00172044 | 00205090 | 00205095 |
| E3/5834 | | 00427971-00427981; 00434687- | Written Record of Witness Interview HAM Samnag | P | 00427972 00427974 | 00434688 00434689 00434690 | 00434699 00434700 00434701 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | | 00434697;<br>00434698-<br>00434708 | | | | | |
| E3/5853 | D40/20 | 00165328-<br>00165336;<br>00433567-<br>00433575;<br>00524316-<br>00524324 | Written Record of Interview of Witness SAING Sim | C | 00165329 | 00433568 | 00524317 |
| E319.1.3<br>3 | | 00968170-<br>00968196<br>00980277-<br>00980305<br>00982607-<br>00982632 | Written Record of Interview of Witness [2-TCW-847] | S | 00968173<br>00968174 | 00980280 | 00982610 |
| E3/2120 | | N/A<br>00416302-<br>00416468<br>N/A | Official Published Version] Book by MENG-TRY Ea entitled "The Chain of Terror: The Khmer Rouge Southwest Zone Security System" | P | N/A | 00416390 | N/A |
| E3/2109 | | 00068014-<br>00068016<br>00276555-<br>00276556<br>00290272-<br>00290274 | Report on prisoners by late November 1977 | P | 00068014 | 00276555 | 00290272 |
| E3/5830 | | 00365692-<br>00365692<br>00363333-<br>00363333;<br>00371259-<br>00371259 | Annex D: Plan of Kraing Ta Chan Security Centre compiled from information provided by witness SAY Sen | P | 00365692 | 00363333 | 00371259 |

<u>**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**</u>

- អនុញ្ញាតឱ្យជនជាប់ចោទ នួន ជា បន្តតាមដានកិច្ចដំណើរនីតិវិធីសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនក្រោមសាលសវនាការ ហើយបង្គាប់ឱ្យអ្នកជំនាញតំឡើងឧបករណ៍សោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា ដើម្បីបន្តតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។ (០៩.១១)
- សម្រេចធ្វើសវនាការជាអសារណៈដោយអនុលោមតាមវិធាន ២៩ នៃវិធានផ្ទៃក្នុង។ បង្គាប់ឱ្យផ្នែកសោតទស្សន៍ផ្តាច់សម្លេង និងរូបភាពចេញទៅក្រៅសវនាការ។ (០៩.១៣)
- សម្រេចផ្តល់វិធានការការពារតាមសំណើសុំវិធានការការពាររបស់សាក្សី 2-TCW-944។ (១០.៣១)
- បង្គាប់ឱ្យផ្នែកសោតទស្សន៍បំផ្លែងរូបភាពមុខរបស់សាក្សីនៅក្នុងអំឡុងពេលដំណើរការសវនាការ។

(១០.៣២)។

- បង្គាប់ឱ្យខាងផ្សព្វផ្សាយព័ត៌មាន មិនត្រូវផ្សព្វផ្សាយដល់សាធារណជននូវរូបថតរបស់សាក្សីនេះ ទោះបីជារូបភាពពីមុនក៏ដោយ។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និង ខៀវ សំផន ត្រឡប់ទៅមន្ទីរឃុំឃាំងវិញ និងបង្គាប់ឱ្យនាំខ្លួនគាត់ មកសាលសវនាការវិញឱ្យបានមុនម៉ោង ០៩ ព្រឹក នៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ។

| **កាលវេលាសវនាការបន្ត** |
|---|
| សវនាការនឹងបន្តទៅថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចាប់ផ្ដើមពីម៉ោង ៩.០០ ព្រឹក។ |

ភ្នំពេញ ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១៥

ក្រឡាបញ្ជី ក្រឡាបញ្ជី

ជា ស៊ីន... Roger PHILLIPS